ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សង្ខេប

## ស្តីពី

## ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២៣

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

រៀបចំដោយ ៖ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ ៖ ថវិកាជាតិ

## ១.សេចក្តីផ្តើម

ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២៣ នាឆ្នាំនេះបានប្រារព្ធឡើងក្រោមប្រធានបទ **"សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍"** បានប្រព្រឹត្តិទៅនាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាព **ឯកឧត្តម វង្សី វិសុទ្ធ** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត**។ អង្គពិធីក៏មានការអញ្ជើញចូលរួមពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំ មន្ត្រីអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍តាមក្រសួងស្ថាប័ន និងសមាជិក សមាជិកាក្រុមប្រឹក្សាបច្ចេកទេស កងកម្លាំងខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ យុវជនកាកបាទក្រហមកម្ពុជា ក្រុមយុវជន ស.ស.យ.ក អង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ក្រុមប្រជាជនគន្លឹះ និងបណ្តាញអ្នកផ្ទុកមេរោគអេដស៍ចំនួនប្រមាណ៤០០នាក់។



## ២.របៀបវារៈ

ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២៣ បានប្រព្រឹត្តទៅតាមរបៀបវារៈដូចខាងក្រោម៖

- ចំណាប់អារម្មណ៍របស់ អ្នកស្រី **ហាន សៀងហ៊ីន** តំណាងអ្នកផ្ទុកមេរោគអេដស៍
- ចំណាប់អារម្មណ៍របស់ លោក **ដួច សុខចំរើន** តំណាងគណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ (HACC)។
- ចំណាប់អារម្មណ៍របស់ លោកស្រី Patricia Ongpin នាយិកាកម្មវិធីសហប្រជាជាតិរួមគ្នាស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ (UNAIDS) ប្រចាំនៅកម្ពុជា។
- សារលិខិត **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិ នៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា ដោយ លោកជំទាវ **ពុំ ចន្ទីនី** អគ្គលេខាធិការកាកបាទក្រហមកម្ពុជា និងជាអនុប្រធានក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិ។
- របាយការណ៍សង្ខេបស្តីពីការងារប្រយុទ្ធទប់ស្កាត់ការរីករាលដាល និងស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជាឆ្នាំ២០២៣ និងសារលិខិត**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- សុន្ទរកថា និងអនុសាសន៍ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត។**

## ៣. ដំណើរការកិច្ចប្រជុំ

៣.១. ជាកិច្ចចាប់ផ្តើម អ្នកស្រី **ហាន សៀងហ៊ីន** តំណាងអ្នករស់នៅជាមួយមេរោគអេដស៍ ក្នុងព្រះរាជាណាចក្រកម្ពុជា បានសម្តែងនូវសេចក្តីសោមនស្សរីករាយ និងមានកិត្តិយសសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ អង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ ក្នុងការរៀបចំប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៣ នាពេលនេះ។ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ថែទាំ ព្យាបាលសុខភាព និងផ្តល់ការគាំទ្រ ទាំងផ្នែកសម្ភារ ស្មារតី និងផ្នែកសង្គម ដល់បងប្អូនដែលរស់នៅជាមួយមេរោគអេដស៍អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ។ ការចូលរួមជាលក្ខណៈពហុវិស័យនេះ ជាកត្តារួមចំណែក កាត់បន្ថយអត្រាឆ្លងមេរោគអេដស៍ពី១.៧% ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹម០.៦% ក្នុងឆ្នាំ២០២២ ក្នុងនោះក៏មានការចូលរួមយ៉ាងសកម្មរបស់

បងប្អូនអ្នករស់នៅជាមួយមេរោគអេដស៍ក្នុងការឆ្លើយតបបញ្ហាអេដស៍នៅគ្រប់កម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកម្រិតសហគមន៍។

បច្ចុប្បន្ននេះ បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍ បានចូលរួមប្រឹងប្រែង អប់រំលើកកម្ពស់ទាំងផ្លូវកាយ និងផ្លូវចិត្ត ដល់បងប្អូនអ្នករស់នៅជាមួយមេរោគអេដស៍ បានមួយចំណែកធំក្នុងចំណោមអ្នករស់នៅជាមួយនឹងមេរោគអេដស៍ជាង៦ម៉ឺននាក់ ដោយបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយគាំទ្រ ការយកចិត្តទុកដាក់ និងធ្វើជាតំណាងទាំងថ្នាក់ជាតិ និងអន្តរជាតិ ក្នុងការកៀរគរស្វែងរកការគាំទ្រជាពហុវិស័យ។ ជាក់ស្តែង នាពេលកន្លងមកនេះ ប្រទេសកម្ពុជាយើងបានជួបប្រទះនូវវិបត្តិជំងឺកូវីដ-១៩ ដែលធ្វើឱ្យបងប្អូនអ្នករស់នៅជាមួយមេរោគអេដស៍ មានការព្រួយបារម្ភជាខ្លាំងជាងបងប្អូនពលរដ្ឋទូទៅ ដោយសារត្រូវការថ្នាំលេបជាប់លាប់ ត្រឹមត្រូវ ជារៀងរាល់ថ្ងៃ ដោយមិនអាចអាក់ខាន។ ដោយសារមានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលតាមរយៈការដឹកនាំ ប្រកបដោយភាពវៃឆ្លាត និងការគិតគូរវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ក្រោមការសម្របសម្រួលរបស់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ រួមជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ព្រមទាំងសហគមន៍ផងនោះ បានចូលរួមគាំទ្រយ៉ាងសកម្មនាំឱ្យបងប្អូនដែលរស់នៅជាមួយមេរោគអេដស៍ បានទទួលកញ្ចប់ថវិកាជំនួយកូវីដ-១៩ បានទាន់ពេលវេលា។ លើសពីនេះទៀត បងប្អូនអ្នករស់នៅជាមួយមេរោគអេដស៍ តែងទទួលបាននូវប័ណ្ណក្រីក្រ ដែលបានសម្រួលជាមធ្យោបាយគាំទ្រឱ្យពួកគាត់មកទទួលសេវាសុខភាពមានប្រសិទ្ធភាព និងទទួលសេវាឱសថប្រឆាំងមេរោគអេដស៍ ដែលជាតម្រូវការអស់មួយជីវិតរបស់ពួកគាត់។ ការខិតខំប្រឹងប្រែងទាំងអស់នេះ ពិតជាបានឆ្លើយតបនឹងយុទ្ធសាស្ត្រឈានទៅសម្រេចបាននូវគោលដៅ៩៥-៩៥-៩៥ (ជាពិសេសត្រូវយកចិត្តទុកដាក់លើ ៩៥% ទី១ ដែលមិនទាន់សម្រេចបានតាមគោលដៅ)។ ជាការពិត ទោះបីជាអត្រាប្រេវ៉ាឡង់បន្តធ្លាក់ចុះទាបយ៉ាងនេះក្តី ក៏បងប្អូនដែលរស់នៅជាមួយមេរោគអេដស៍ នៅតែត្រូវការសេវាសុខភាពប្រកបដោយគុណភាព ប្រសិទ្ធភាព ភាពរួសរាយរាក់ទាក់ គ្មានការរើសអើង។ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ រហូតមកដល់ពេលនេះ មានចំនួនរហូតដល់ជាង៦ម៉ឺននាក់ រួមទាំងកុមារផងដែរ។ សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ ប៉ុន្តែសេវាថែទាំ និងគាំទ្រសង្គមផ្សេងៗមួយចំនួនទៀត ក៏ជាតម្រូវការចាំបាច់សម្រាប់បងប្អូនរស់នៅជាមួយមេរោគអេដស៍ ដូចជា អាហារូបត្ថម្ភ ការទទួលបានការងារសមរម្យ ទីជម្រក សេវាផ្នែកច្បាប់។ល។ ទន្ទឹមនឹងភាពជោគជ័យទាំងនេះ អ្នករស់នៅជាមួយមេរោគអេដស៍ ក៏នៅមានក្តីព្រួយបារម្ភមួយទៀតដោយសារតែការកាត់បន្ថយជំនួយយ៉ាងគំហុក អាចនាំឱ្យសកម្មភាពមួយចំនួនអនុវត្តមិនបានពេញលេញ ឬ

បញ្ឈប់តែម្តង ជាពិសេសការសម្របសម្រួលនៅកន្លែងផ្តល់សេវាឱសថប្រឆាំងមេរោគអេដស៍ ដែលកន្លងមក អនុវត្តដោយអ្នករស់នៅជាមួយមេរោគអេដស៍ផ្ទាល់ជាច្រើនឆ្នាំ តែបច្ចុប្បន្នត្រូវបានកាត់បន្ថយយ៉ាងច្រើន។ ក្នុងនាមតំណាងឱ្យអ្នកផ្ទុកមេរោគអេដស៍ និងអ្នករស់នៅជាមួយមេរោគអេដស៍ សូមរាជរដ្ឋាភិបាល ម្ចាស់ជំនួយ បន្តការគាំទ្រថវិកាក្នុងការអនុវត្តសកម្មភាពរបស់អ្នករស់នៅជាមួយមេរោគអេដស៍ ក្រុមងាយរងគ្រោះ ដោយពេញទំហឹង និងទទួលបាននូវកិច្ចគាំពារសង្គមថែមទៀត ដើម្បីឱ្យជីវភាពរស់នៅរបស់ពួកគាត់ កាន់តែប្រសើរឡើង ដែលអាចនាំឱ្យពួកគាត់មិនធ្វើចំណាកស្រុក និងមិនបោះបង់ការលេបថ្នាំជាដើម។

៣.២. ជាកិច្ចបន្ត លោក **ជួប សុខចំរើន** ប្រធានគណៈកម្មាធិការដឹកនាំគណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព ជាតំណាងអង្គការសង្គមស៊ីវិលកំពុងអនុវត្តន៍កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងជានាយកប្រតិបត្តិអង្គការខាណា បានមានចំណាប់អារម្មណ៍ថា ក្នុងនាមអង្គការសង្គមស៊ីវិល ដែលបាន និងកំពុងអនុវត្តន៍កម្មវិធីលើកកម្ពស់សុខភាព ជាពិសេសកម្មវិធីប្រយុទ្ធទៅនឹងជំងឺអេដស៍នៅកម្ពុជា មានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមជាកិត្តិយស និងថ្លែងមតិក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៣ នាថ្ងៃនេះ ដែលប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសដទៃទៀត នៅលើពិភពលោកបាន និងកំពុងរៀបចំក្រោមប្រធានបទ "**សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍**"។

ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ គឺត្រូវបានរៀបចំឡើង ដើម្បីបង្ហាញពីការចូលរួម និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកដែលកំពុងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ក៏ដូចជាបង្ហាញពីកិច្ចខិតខំប្រឹងប្រែងនៃការចូលរួមជាពហុវិស័យរបស់ស្ថាប័នពាក់ព័ន្ធ ក្នុងការទប់ស្កាត់ និងលុបបំបាត់ការរីករាលដាលនៃមេរោគអេដស៍ឱ្យសម្រេចបាននូវគោលដៅដែលបានគ្រោងទុកនៅឆ្នាំ២០៣០។

ក្នុងនាមអង្គការសង្គមស៊ីវិលទាំងអស់ ដែលបាន និងកំពុងអនុវត្តន៍កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ សូមបន្តប្តេជ្ញា និងចូលរួមឱ្យបានសកម្មបន្ថែមទៀត ដើម្បីឱ្យកម្ពុជាសម្រេចបាននូវគោលដៅ៩៥ទាំងបី នៅឆ្នាំ២០២៥តាមកាលកំណត់ និងបន្តឱ្យកាន់តែសកម្មក្នុងការស្វែងរកអ្នកដែលមានផ្ទុកមេរោគអេដស៍ ជាពិសេសក្រុមអ្នកស្រឡាញ់ភេទដូចគ្នាវ័យក្មេង ដែលមិនទាន់បានដឹងស្ថានភាពរបស់ខ្លួននៅឡើយ ហើយជួយពួកគេឱ្យឆាប់ទទួលបានការធ្វើតេស្តឈាមរកមេរោគអេដស៍ និងឆាប់ទទួលបាន និងទទួលយកនូវការព្យាបាល នៅតាមមន្ទីរពេទ្យបង្អែកនៅទូទាំងប្រទេស។

ឆ្លៀតក្នុងឱកាសនេះផងដែរ ក្នុងនាមអង្គការសង្គមស៊ីវិលដែលបាន និងកំពុងអនុវត្តន៍កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងកម្មវិធីសុខភាពទូទៅ សូមចូលរួមអបអរសាទរយ៉ាងជ្រាលជ្រៅជូនដល់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលបានទទួលការគាំទ្រពីប្រជាជនកម្ពុជា ច្រើនលើសលប់ក្នុងការជ្រើសរើសជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់អាណត្តិទី៧។

ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២៣ ក្រោមប្រធានបទ "**សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍**" បានបញ្ជាក់ឱ្យឃើញនូវភាពចាំបាច់របស់សហគមន៍ក្នុងការចូលរួមឱ្យរឹតតែសកម្មក្នុងការចូលរួមអនុវត្ត និងតាមដាន ដើម្បីចូលរួមឆ្ពោះទៅរកគោលដៅបញ្ចប់ការរាតត្បាតនៃមេរោគអេដស៍នៅឆ្នាំ២០៣០។ កន្លងមកសហគមន៍បាននឹងកំពុងចូលរួមយ៉ាងសកម្មក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការចូលរួមអប់រំផ្សព្វផ្សាយ ការស្វែងរកក្រុមប្រឈម ដើម្បីធ្វើតេស្តរកមេរោគអេដស៍ និងក៏ដូចជាបញ្ជូនពួកគេទៅរកសេវាព្យាបាល និងគាំទ្រពាក់ព័ន្ធទៅនឹងការទទួលសេវា។ ក្រៅពីការផ្តល់សេវាខាងផ្នែកបង្ការ និងការអប់រំ ខាងសហគមន៍ ក៏បានចូលរួមយ៉ាងសកម្មក្នុងការផ្តល់នូវការថែទាំ និងការគាំទ្រ ដោយពួកគេមានតួនាទីជាអ្នកគ្រប់គ្រងទិន្នន័យ ការតាមដានបន្ត ការរម្លឹកសហគមន៍របស់ពួកគេ ឱ្យមកទទួលសេវាតាមការណាត់របស់គ្រូពេទ្យ។ ជាងនេះទៅទៀត ខាងតំណាងសហគមន៍ពួកគេក៏បានចូលរួមសកម្មភាពផងដែរ ក្នុងការជ្រើសរើសតំណាង ការទៅយកថ្នាំពីកន្លែងផ្តល់សេវាសុខាភិបាលដែលពួកគេ កំពុងរស់នៅតាមសហគមន៍។ ជាងនេះទៅទៀតនោះ តំណាងសហគមន៍ បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត ការតាមដានដោយសហគមន៍ ហៅថា(Community Led Monitoring) ដែលជាយន្តការមួយក្នុងការប្រមូលទិន្នន័យពីសហគមន៍ ដើម្បីចែករំលែកដល់អ្នកដែលកំពុងអនុវត្តគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធនានាក្នុងការពង្រឹងសេវា ដើម្បីឆ្លើយតបទៅនឹងតម្រូវការកំពុងជួបប្រទះ។

ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ អំពាវនាវឱ្យមានការរួមដៃគ្នារវាងអ្នកដឹកនាំនយោបាយ និងពលរដ្ឋទាំងអស់ ទទួលស្គាល់ និងឆ្លើយតបចំពោះវិសមភាព ដែលអាចឱ្យវឌ្ឍនភាពកើតមានឡើងវិញក្នុងការបញ្ចប់ការរាតត្បាតមេរោគអេដស៍ និងត្រូវធ្វើឱ្យមានសមភាព ក្នុងការទទួលបានសេវាចាំបាច់ដែលពាក់ព័ន្ធនឹងមេរោគអេដស៍ សម្រាប់ក្រុមអ្នកប្រឈមមុខខ្ពស់នៃការឆ្លងមេរោគអេដស៍ ដែលរួមមានបុរសរួមភេទជាមួយបុរស ក្រុមអ្នកបំប្លែងភេទ ក្រុមជនរងគ្រោះនៃការប្រើបំពានគ្រឿងញៀន ក្រុមស្ត្រីបម្រើការនៅតាមសេវាកម្សាន្ត និងអ្នកដៃគូរបស់ពួកគេ។ ជាងនេះទៅទៀត ការចូលរួមរបស់សហគមន៍ក្នុងការដឹកនាំ និងអនុវត្តសកម្មភាពនានាដែលជាធាតុចូលដ៏សំខាន់មួយក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ ក៏ដូចជាចូលរួមក្នុងការធ្វើឱ្យមាននិរន្តភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ផងដែរ។

ក្នុងគោលដៅកម្ពុជាឆ្ពោះទៅសម្រេចបានការលុបបំបាត់ការឆ្លងមេរោគថ្មីនាឆ្នាំ២០២៥ នៃគោលដៅ ៩៥% ៩៥% និង៩៥% អង្គការសង្គមស៊ីវិលផ្នែកសុខភាព មានជំនឿយ៉ាងមុតមាំថា កម្ពុជាពិតជាអាចធ្វើបាន ដោយបន្តនូវយុទ្ធសាស្ត្រឆ្លើយតបទៅនឹងជំងឺអេដស៍ ជាលក្ខណៈពហុវិស័យ បន្តលុបបំបាត់ គម្លាតរវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវា លុបបំបាត់នូវការប្រមាថមាក់ងាយ ការរើសអើងទៅលើក្រុមអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខដទៃផ្សេងទៀត ទាំងនៅកម្រិតគ្រួសារ សង្គម និងនៅកន្លែងផ្តល់សេវាពាក់ព័ន្ធ បង្កើត និងពង្រឹងឱ្យមានសេវាមេត្រីកាន់តែមានច្រើន នៅគ្រប់មូលដ្ឋានសុខាភិបាល និងផ្តល់ការគាំទ្រលើកទឹកចិត្តដល់អ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខ ឱ្យទទួលបានសេវាបង្ការ ព្យាបាលមេរោគអេដស៍ កាន់តែឆាប់ និងទាន់ពេលវេលា។ នៅក្នុងឆ្នាំ២០២៣ អង្គការសង្គមស៊ីវិលនៅ

តែដើរតួនាទីយ៉ាងសកម្មក្នុងការបន្តផ្តល់សេវាអប់រំ អំពីការបង្ការមេរោគអេដស៍ រួមទាំងផ្តល់ការចែកចាយស្រោមអនាម័យ ឧបករណ៍ធ្វើតេស្តហ៊ីសដោយខ្លួនឯង ផ្តល់ការអប់រំ និងប្រឹក្សាលើការទទួលយកថ្នាំបង្ការជាមុន (PrEP) និងផ្តល់ការថែទាំ និងគាំទ្រទាំងជួបផ្ទាល់ និងពីចម្ងាយ តាមប្រព័ន្ធទំនាក់ទំនង ដូចជាទូរសព្ទ បណ្តាញសង្គម និងមធ្យោបាយទំនាក់ទំនងដទៃផ្សេងទៀតជាច្រើន ដើម្បីធានាថាក្រុមគោលដៅដែលជាក្រុមប្រឈមមុខខ្ពស់ នៃការឆ្លងមេរោគអេដស៍ និងរស់នៅជាមួយមេរោគអេដស៍ នៅតែបន្តទទួលបានសេវាដែលគេត្រូវការ។ បន្ថែមលើការងារថែទាំ និងគាំទ្រ នៅតាមសហគមន៍សម្រាប់អ្នកផ្ទុកមេរោគអេដស៍ អង្គការសង្គមស៊ីវិល ផ្នែកអប់រំបង្ការមេរោគអេដស៍ នៅភូមិភាគខាងជើង និងភូមិភាគខាងត្បូង ដែលមានអង្គការរ៉ាក់ អង្គការខាណា និងដៃគូ ក្នុងរយៈពេលដប់ខែ នៃ ឆ្នាំ២០២២ ដោយគិតពីខែមករា ដល់ខែតុលា ឆ្នាំ២០២២ បានផ្តល់ ៖ ការអប់រំបង្ការដល់ក្រុមប្រឈមមុខខ្ពស់ដែលជាស្ត្រីបម្រើសេវាកម្សាន្តបុរសរួមភេទជាមួយបុរស និងក្រុមអ្នកបំប្លែងភេទ សរុបបានចំនួន**៨៤.៦០៩នាក់** (តាមរយៈរបាយការណ៍អង្គការខាណា និងអង្គការរ៉ាក់) ដោយរកឃើញមានអ្នកផ្ទុកមេរោគអេដស៍ចំនួន**១.៧៥៩នាក់**។ បន្ថែមលើនេះទៀតការផ្តល់ជំនួយបច្ចេកទេស និងជួយគាំទ្រផ្នែកហិរញ្ញវត្ថុបន្ត សម្រាប់អង្គការសង្គមស៊ីវិល និងបណ្តាញនៃអ្នករស់នៅជាមួយមេរោគអេដស៍ និងបណ្តាញនៃក្រុមប្រឈមមុខខ្ពស់ និងការពង្រឹងពង្រីកភាពជាដៃគូ រវាងរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធជាមួយពួកគេ នឹងជួយឱ្យអង្គការសង្គមស៊ីវិល និងក្រុមបណ្តាញនៃអ្នករស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់ កាន់តែមានភាពសកម្មស្វាហាប់ និងជាការលើកទឹកចិត្តក្នុងការបន្តស្វែងរក និងជួយដល់អ្នកមិនទាន់ធ្វើរោគវិនិច្ឆ័យ ជាពិសេសក្រុមវ័យក្មេងនៃក្រុមអ្នកស្រឡាញ់និងរួមភេទជាមួយគ្នា បានធ្វើតេស្តឈាម និងទទួលបានការព្យាបាលទាន់ពេលវេលា ដែលជួយឱ្យពួកគេស្ថិតក្នុងការព្យាបាលជាប់លាប់រហូតដល់បន្ទុកមេរោគអេដស៍មានការថយចុះ ឬរកមិនឃើញ ដើម្បីឱ្យកម្ពុជាបន្តទទួលបានជោគជ័យ លើគោលដៅដែលបានគ្រោងទុក អង្គការសង្គមស៊ីវិល ក៏សូមឆ្លៀតឱកាសនេះសូមសំណូមពរដូចខាងក្រោម៖

១. បន្តលើកកម្ពស់ និងគាំទ្រតួនាទីរបស់អ្នករស់នៅជាមួយមេរោគអេដស៍ លើការផ្តល់សេវាព្យាបាលដល់សហគមន៍ពួកគេ រួមមានទាំងតួនាទីក្នុងការផ្តល់ឱសថ និងការតាមដាននូវការវិវត្តន៍នូវបន្ទុកមេរោគអេដស៍ ដល់ក្រុមអ្នកផ្ទុកមេរោគអេដស៍ ដែលមានស្ថានភាពសុខភាពល្អប្រសើរ។

២. បន្តពង្រីកសេវាប្រែប (PrEP) នៅតាមសហគមន៍ ឱ្យបានទូលំទូលាយដល់ក្រុមគោលដៅដែលមានហានិភ័យខ្ពស់ក្នុងការឆ្លងមេរោគអេដស៍ ជាពិសេសការផ្តល់តួនាទីឱ្យបណ្តាញក្រុមអប់រំផ្ទាល់នៅតាមសហគមន៍ចូលរួមចំណែកក្នុងការគ្រប់គ្រង និងការផ្តល់សេវានេះសម្រាប់សមាជិករបស់ពួកគេ។

៣. ពង្រីកអន្តរាគមន៍អប់រំបង្ការ ឱ្យបានទូលំទូលាយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយឌីជីថលទាំងរបស់រដ្ឋ និងឯកជន ដល់ក្រុមយុវវ័យដែលងាយនឹងប្រឈមមុខខ្ពស់ក្នុងការឆ្លងមេរោគអេដស៍

ជាមួយនឹងសារដែលមានភាពងាយយល់ ទាក់ទាញ មានការចូលរួមអំពីតារាល្បីៗ ដែលមានការពេញចិត្តពីក្រុមយុវវ័យ និងផ្តល់កញ្ចប់ថវិកាបន្ថែមផ្នែកអប់រំបង្ការ ដល់អង្គការសង្គមស៊ីវិល និងក្រុមប្រឈមមុខខ្ពស់។

៤. ស្នើរាជរដ្ឋាភិបាល អនុវត្តន៍យន្តការកិច្ចសន្យាសង្គម (Social Contracting) ដល់អង្គការសង្គមស៊ីវិលឱ្យមានធនធានបន្តបេសកម្មរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងបញ្ហាមេរោគអេដស៍ ប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព ជាពិសេសសម្រាប់ការងារអប់រំបង្ការលើក្រុមប្រឈមមុខខ្ពស់។

៥. បន្តពង្រីកឱ្យមានការប្រើប្រាស់ថវិកាឃុំ សង្កាត់ ដើម្បីអនុវត្តន៍កម្មវិធីអេដស៍នៅតាមសហគមន៍ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល។

៦. បន្តពង្រឹងយន្តការសម្របសម្រួលការងារឆ្លើយតបនឹងមេរោគអេដស៍ទាំងក្នុងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យមានជាប្រចាំ ដើម្បីធានាឱ្យមានការចូលរួមជាពហុវិស័យពីស្ថាប័នពាក់ព័ន្ធក្នុងការទទួលបានព័ត៌មានបច្ចុប្បន្នភាពនៃមេរោគអេដស៍ និងជំងឺអេដស៍ ក៏ដូចជាចូលរួមដោះស្រាយបញ្ហាដែលកំពុងកើតមានឡើងផងដែរ។

៧. សំណូមពរ និងឱ្យមានការលើកទឹកចិត្តដល់បងប្អូនដែលមានការសង្ស័យថាមានផ្ទុកមេរោគអេដស៍ សូមឆាប់ទៅទទួលយកសេវាប្រឹក្សា និងធ្វើតេស្តឈាមដែលមាននៅតាមសហគមន៍ និងនៅតាមមន្ទីរពេទ្យបង្អែកនៅទូទាំងប្រទេស ហើយឆាប់ទទួលយកការព្យាបាល និងព្យាបាលជាប់លាប់ ដើម្បីសុខភាពបុគ្គលខ្លួនឯង មនុស្សជាទីស្រឡាញ់ គ្រួសារ និងសហគមន៍។

ក្នុងនាមអង្គការសង្គមស៊ីវិល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត និងលោកជំទាវបណ្ឌិតពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលតែងតែបានយកចិត្តទុកដាក់ និងផ្តល់ការគាំទ្រក្នុងការងារប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ដែលធ្វើឱ្យកម្ពុជាទទួលជោគជ័យលើការងារនេះទាំងនៅក្នុងតំបន់ និងទាំងនៅលើសកលលោក និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងថ្នាក់ដឹកនាំទាំងអស់ដែលបានបង្កភាពងាយស្រួល និងផ្តល់ការគាំទ្រ នូវការចូលរួមរបស់សហគមន៍ និងអង្គការសង្គមស៊ីវិល ក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍។ សូមថ្លែងអំណរគុណឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអាជ្ញាធរមូលដ្ឋាននៅគ្រប់ជាន់ថ្នាក់ ព្រមទាំងក្រសួងមន្ទីរពាក់ព័ន្ធ សម្រាប់ការជួយជ្រោមជ្រែង និងការសហការដ៏រលូន ដែលធ្វើឱ្យសហគមន៍ និងអង្គការសង្គមស៊ីវិល ដំណើរការកម្មវិធីរបស់ខ្លួនប្រកបដោយជោគជ័យ និងសូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយ រួមមាន USAID, GFATM មូលនិធិប្រទេសបារាំង

(L'Initiative/Expertise France) និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត សម្រាប់ការជួយគាំទ្រនានា ក្នុងការជួយសង្គ្រោះជីវិតអ្នករស់នៅជាមួយមេរោគអេដស៍រាប់រយពាន់នាក់បន្តរស់បាន និងកសាងជីវភាពរស់នៅជាប្រក្រតីឡើងវិញនៅក្នុងសហគមន៍។

៣.៣. បន្ទាប់មកទៀតជាចំណាប់អារម្មណ៍របស់ លោកស្រី **Patricia Ongpin** នាយិកាកម្មវិធីសហប្រជាជាតិរួមគ្នាស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ (UNAIDS) ប្រចាំនៅកម្ពុជា ៖

តាងនាមឱ្យ UNAIDS និងក្រុមការងាររួមគ្នារបស់អង្គការសហប្រជាជាតិទទួលបន្ទុកលើការងារឆ្លើយតបនឹងមេរោគអេដស៍នៅកម្ពុជា ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលបានចូលរួមជាមួយអ្នកទាំងអស់គ្នានាថ្ងៃនេះ ដើម្បីប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ ២០២៣។ ជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៨៨មក ថ្ងៃ១ធ្នូ គឺជាថ្ងៃសម្រាប់មនុស្សទូទាំងពិភពលោក រួបរួមគ្នាបង្ហាញការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនដែលរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងដើម្បីរម្លឹកដល់អ្នកដែលបានបាត់បង់ជីវិតដោយសារជំងឺអេដស៍។ ប្រធានបទជាសកលសម្រាប់ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ក្នុងឆ្នាំនេះ គឺ **«សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍»**។ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ គឺលើសពីការអបអរសាទរទៅលើសមិទ្ធផលរបស់សហគមន៍ ហើយទិវាពិភពលោកនេះ ក៏ជាការអំពាវនាវឱ្យមានសកម្មភាព ដើម្បីជំរុញ និងគាំទ្រសហគមន៍ក្នុងតួនាទីដឹកនាំរបស់ពួកគេ។ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២៣ បង្ហាញពីតម្រូវការក្នុងការបញ្ចេញសក្តានុពលពេញលេញនៃភាពជាអ្នកដឹកនាំរបស់សហគមន៍ ដើម្បីអាចបញ្ចប់ជំងឺអេដស៍។

- តួនាទីភាពជាអ្នកដឹកនាំរបស់សហគមន៍ ចាំបាច់ត្រូវបង្កើតជាស្នូលនៅក្នុងផែនការ និងកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ទាំងអស់ និងនៅក្នុងការបង្កើតផែនការ និងកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ទាំងនោះ ការរៀបចំថវិកា ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ។ ហេតុដូចនេះហើយវាមានសារៈសំខាន់ដែលយើងត្រូវចងចាំ ពាក្យស្លោក «គ្មានអ្វីសម្រាប់ពួកគេ ប្រសិនបើគ្មានពួកគេ» ។
- តួនាទីភាពជាអ្នកដឹកនាំរបស់សហគមន៍ ចាំបាច់ត្រូវទទួលបានការគាំទ្រមូលនិធិយ៉ាងពេញលេញ និងប្រកបដោយទំនុកចិត្ត ដើម្បីអាចបង្កើនទំហំសហគមន៍ទៅតាមតម្រូវការ ហើយសហគមន៍ក៏ត្រូវទទួលបានការគាំទ្រ និងកម្រៃសមរម្យទៅតាមការងាររបស់ពួកគេ នេះក៏ព្រោះតែ «ការមិនបញ្ចប់ជំងឺអេដស៍ គឺថ្លៃជាងការបញ្ចប់ជំងឺនេះទៅទៀត»។
- រនាំងឧបសគ្គចំពោះតួនាទីភាពជាអ្នកដឹកនាំរបស់សហគមន៍ចាំបាច់ត្រូវដកចេញ។ ការអនុញ្ញាតឱ្យបរិយាកាសច្បាប់មានលក្ខណៈអំណោយផល គឺត្រូវការជាចាំបាច់ ដែលអាចសម្រួលតួនាទីរបស់សហគមន៍ក្នុងការផ្តល់សេវាមេរោគអេដស៍ ធានាការចូលរួមរបស់អង្គការសង្គមស៊ីវិល និងការពារសិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់រូប រួមមានសហគមន៍ងាយរងគ្រោះ ដើម្បីជំរុញការឆ្លើយតបនឹងមេរោគ

អេដស៍។ យើងចាំបាច់ត្រូវតែ «លុបបំបាត់ច្បាប់ដែលអាចបង្កគ្រោះថ្នាក់ ហើយបង្កើតច្បាប់ដែលផ្តល់អំណាចដល់សហគមន៍»។ សហគមន៍គឺជាភ្នែក ត្រចៀក និងបេះដូងនៃការឆ្លើយតបនឹងមេរោគអេដស៍ ពួកគេគឺជាគន្លឹះក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏ប៉ុន្តែជាញឹកញាប់ ពួកគេខ្វះខាតធនធាន និងការទទួលស្គាល់ដែលពួកគេត្រូវការ និងសមនឹងទទួលបាន។ សហគមន៍ភ្ជាប់ប្រជាពលរដ្ឋជាមួយនឹងសេវាសុខាភិបាលសាធារណៈ ដែលផ្តោតលើតម្រូវការអ្នកមកទទួលសេវា បង្កើតទំនុកចិត្ត ភាពច្នៃប្រឌិត តាមដានការអនុវត្តគោលនយោបាយ និងសេវាកម្ម និងធ្វើឱ្យអ្នកផ្តល់សេវាមានទំនួលខុសត្រូវ។ ភាពជាអ្នកដឹកនាំ និងការតស៊ូមតិរបស់ពួកគេធានាថា ការឆ្លើយតបនឹងមេរោអេដស៍គឺនៅតែស្ថិតក្នុងគោលការណ៍នៃការផ្តោតសំខាន់លើប្រជាពលរដ្ឋក្នុងសហគមន៍ និងមិនទុកនរណាម្នាក់ចោល។

នៅក្នុងប្រទេសកម្ពុជា សហគមន៍រួមមាន ក្រុមការងារ និងអ្នកចុះផ្សព្វផ្សាយសហគមន៍ អ្នកប្រឹក្សា និងបុគ្គលិកសុខាភិបាលសហគមន៍។ សហគមន៍ក៏ជាបណ្តាញនៃអ្នកផ្ទុកមេរោគអេដស៍ ឬអ្នករងផលប៉ះពាល់ដោយមេរោគអេដស៍ ដូចជាអ្នកបម្រើសេវាកម្សាន្ត និងបុរសរួមភេទជាមួយបុរស ស្ត្រីបំប្លែងភេទ អ្នកប្រើប្រាស់ និងចាក់គ្រឿងញៀន ស្ត្រី និងយុវជន ហើយសហគមន៍ក៏មានការចូលរួមពីអង្គការសង្គមស៊ីវិល និងសកម្មជនមូលដ្ឋានផងដែរ។ ការឆ្លើយតបនឹងមេរោគអេដស៍របស់កម្ពុជា មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ហើយសហគមន៍ក៏បានចូលរួមក្នុងដំណើរវឌ្ឍនភាពនេះគ្រប់ដំហាន។

ប្រទេសកម្ពុជា ធ្លាប់ជាប្រទេសដែលមានការរីករាលដាលមេរោគអេដស៍លឿនបំផុត នៅក្នុងតំបន់ ហើយក៏បានប្រែក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដំបូងគេនៅលើពិភពលោក ដែលសម្រេចបាននូវគោលដៅពិភពលោក ៩០-៩០-៩០។ ភាពជោគជ័យរបស់ប្រទេសកម្ពុជាបានចាក់ឫសនៅក្នុងភាពជាដៃគូ ភាពច្នៃប្រឌិត ការគោរពសិទ្ធិមនុស្ស និងសមភាពយេនឌ័រ ភាពជាអ្នកដឹកនាំ និងការចូលរួមរបស់សហគមន៍ ដោយប្រើប្រាស់ដំណោះស្រាយដែលផ្អែកលើសហគមន៍ ការប្តេជ្ញាចិត្តផ្នែកនយោបាយ និងការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ខណៈដែលយើងមានសមិទ្ធផលជាច្រើន ដើម្បីអបអរសាទរដល់កម្ពុជាក្នុងដំណើរនៃការឆ្លើយតបនឹងមេរោគអេដស៍ កម្ពុជាក៏ដឹងយ៉ាងច្បាស់ថា នៅមានសកម្មភាពច្រើនទៀតដែលត្រូវធ្វើ ដើម្បីបញ្ចប់ការរីករាលដាលនៃជំងឺអេដស៍ ដែលជាការគំរាមកំហែងដល់សុខភាពសាធារណៈ និងការឆ្លើយតបនឹងមេរោគអេដស៍ប្រកបដោយចីរភាព។

ក្នុងឆ្នាំ២០២២ កម្ពុជាមានអ្នកផ្ទុកមេរោគអេដស៍ប្រហែល ៧៦.០០០នាក់ ដែលក្នុងនោះ ៨៦% បានដឹងពីស្ថានភាពមេរោគអេដស៍របស់ពួកគេ និងទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ហើយ៩៨% មានបន្ទុកមេរោគអេដស៍ទាបបំផុត។ ប្រទេសកម្ពុជា ជាប្រទេសមួយ ក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលមានការគ្របដណ្តប់ដោយសេវាព្យាបាលមេរោគអេដស៍ខ្ពស់បំផុត ទោះជាយ៉ាងនេះក្តី អ្នកផ្ទុកមេរោគអេដស៍ប្រមាណ១១.០០០នាក់ នៅតែមិនទាន់បានធ្វើរោគវិនិច្ឆ័យនៅ

កម្ពុជា។ យើងសង្កេតឃើញថា ភាពងាយរងគ្រោះលើការឆ្លងមេរោគអេដស៍ មានការកើនឡើងនៅក្នុងចំណោមប្រជាជនគន្លឹះវ័យក្មេង ដែលមានអាយុពី ១៥-២៤ឆ្នាំ ដែល ៤៣% នៃករណីឆ្លងមេរោគអេដស៍ថ្មីក្នុងឆ្នាំ២០២២ ស្ថិតក្នុងចំណោមក្រុមប្រជាជនគន្លឹះនេះ។

ជារៀងរាល់ថ្ងៃក្នុងឆ្នាំ២០២២ ប្រទេសកម្ពុជា មានមនុស្សប្រហែល៤នាក់ បានឆ្លងមេរោគអេដស៍ និងមនុស្ស៣នាក់បានស្លាប់ដោយសារជំងឺអេដស៍។ ច្បាស់ណាស់មេរោគអេដស៍នៅតែរាតត្បាតក្នុងប្រទេសកម្ពុជា ដែលយើងត្រូវតែបន្តដោះស្រាយជាមួយគ្នាជាចាំបាច់។ ដូច្នេះតើមានសកម្មភាពអ្វីខ្លះទៀត ដែលយើងត្រូវធ្វើ? ការឆ្លើយតបមេរោគអេដស៍ពហុវិស័យផ្អែកលើភស្តុតាងរបស់កម្ពុជា មានព័ត៌មានជាច្រើន ដែល បង្ហាញពីគម្លាតដែលយើងត្រូវតែដោះស្រាយ និងអន្តរាគមន៍មួយចំនួន ដែលត្រូវកែសម្រួលឱ្យប្រសើរឡើង ដើម្បីគ្រប់គ្រងការរីករាលដាលៈ

- ចាំបាច់រួមគ្នាធានាឱ្យបាននូវការប្តេជ្ញាចិត្តខាងផ្នែកនយោបាយ និងការដឹកនាំគ្រប់កម្រិត និងគ្រប់វិស័យ ដើម្បីបញ្ចប់ការរីករាលដាលនៃជំងឺអេដស៍។
- ចាំបាច់រួមគ្នានាំយកបច្ចេកវិទ្យាថ្មី និងគំរូនៃការផ្តល់សេវាដែលមានលក្ខណៈខុសប្លែកគ្នា ដើម្បីពង្រីកសកម្មភាព រួមមាន បទអន្តរាគមន៍តាមបែបនិម្មិត ឱសថបង្ការការឆ្លងមេរោគអេដស៍មុនពេលប្រព្រឹត្តប្រឈម (PrEP) ទាំងតាមការលេប និងការចាក់ ការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង និងសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជសម្រាប់យុវជន។
- ចាំបាច់រួមគ្នាប្រកាន់ខ្ជាប់នូវវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស ដោះស្រាយវិសមភាព ដែលរារាំងដល់វឌ្ឍនភាព រួមមានច្បាប់ និងគោលនយោបាយ ដែលមានផលប៉ះពាល់ ការមាក់ងាយ និងការរើសអើង និងវិសមភាពយេនឌ័រ។
- ចាំបាច់រួមគ្នាធានាឱ្យបាននូវមូលនិធិក្នុងស្រុកឱ្យបានគ្រប់គ្រាន់ និងប្រកបដោយចីរភាព និងការផ្តោតសំខាន់ ដើម្បីការពារសមិទ្ធផលទៅអនាគត។
- ចាំបាច់រួមគ្នាគាំទ្រ និងបង្កើតភាពជាអ្នកដឹកនាំក្នុងសហគមន៍ និងការឆ្លើយតបដែលដឹកនាំដោយសហគមន៍ រួមទាំងការពង្រឹងសមត្ថភាពរបស់សហគមន៍ក្នុងការផ្តល់សេវាទាក់ទងនឹងមេរោគអេដស៍សម្រាប់ការបង្ការ ការព្យាបាល និងបរិយាកាសអំណោយផលផ្នែកសង្គម។ សហគមន៍របស់យើងគឺជាប្រភពនៃថាមពល ដែលមានសារៈសំខាន់សម្រាប់ការឆ្លើយតបមេរោគអេដស៍ប្រកបដោយចីរភាព ក៏ប៉ុន្តែសក្តានុពលរបស់សហគមន៍ នៅមិនទាន់បានបញ្ចេញអស់នៅឡើយ ការជំរុញបង្កើនសមត្ថភាពសហគមន៍ និងភាពជាអ្នកដឹកនាំ គឺជាចំណុចដែលត្រូវធ្វើឱ្យបានឆាប់រហ័សបំផុតហើយ និងបន្តជំហានឆ្ពោះទៅរកការប្តេជ្ញាចិត្តរបស់កម្ពុជា ហើយកាលណាយើងវិនិយោគកាន់តែច្រើនទៅលើសហគមន៍ យើងកាន់តែខិតទៅជិតការបញ្ចប់ការរីករាលដាលនៃជំងឺអេដស៍។ ដូច្នេះ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍នេះ សូមចងចាំថា យើងចាំបាច់ត្រូវតែឱ្យសហគមន៍ជាអ្នកដឹកនាំ។

៣.៤. បន្ទាប់មកទៀតជាការអាននូវសារលិខិត **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិ នៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា ដោយលោកជំទាវ **ពុំ ចន្ទីនី** អគ្គលេខាធិការកាកបាទក្រហមកម្ពុជា និងជាប្រធានក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិ។ (សូមជូនភ្ជាប់នូវឯកសារ)។

៣.៥. បន្ទាប់មកទៀតជារបាយការណ៍សង្ខេបស្តីពីការងារប្រយុទ្ធទប់ស្កាត់ការរីករាលដាល និងស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាឆ្នាំ២០២៣ ដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

តាងនាមថ្នាក់**ដឹកនាំ**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនឯកឧត្តមផ្ទាល់ មានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានរៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២៣ ក្រោមប្រធានបទ "**សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍**" ដ៏មហោឡារិក នាពេលនេះ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានធ្វើគារវកិច្ចដ៏ឧត្តុង្គឧត្តមចំពោះ **ឯកឧត្តម ចាន់ ថិស្សាត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍នាពេលនេះ។

ជារៀងរាល់ឆ្នាំ ក្នុងនាមរាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍តែងតែរៀបចំការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ នាថ្ងៃទី១ ខែធ្នូ ជារៀងទាត់។ ការប្រារព្ធទិវានេះធ្វើឡើងក្នុងគោលបំណង បង្ហាញការប្តេជ្ញាចិត្តដ៏មុតស្រួចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍។ ក្នុងនោះ យើងរម្លឹកពីការផ្តល់នូវការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងរម្លឹកនូវការសោកស្តាយចំពោះអ្នកស្លាប់ដោយសារជំងឺអេដស៍ ព្រមទាំងក្រើនរម្លឹកដល់ប្រជាពលរដ្ឋទូទាំងប្រទេសឱ្យចងចាំពីគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ដើម្បីទាំងអស់គ្នាឈានទៅលុបបំបាត់ការឆ្លងរីករាលដាលមេរោគអេដស៍ រួមចំណែកក្នុងការអភិវឌ្ឍមនុស្សជាតិ។ ទន្ទឹមនឹងនេះ យើងលើកកម្ពស់ការយល់ដឹងអំពីជំងឺអេដស៍ ដោយបង្ហាញពីសារៈសំខាន់នៃចំណេះដឹងស្តីពីវិធានការបង្ការ និងគ្រប់គ្រងជំងឺអេដស៍ មកដល់ពេលនេះ អេដស៍នៅតែជាជំងឺមួយដែលគំរាមកំហែងដល់សុខភាពសាធារណៈរបស់មនុស្សជាតិនៅឡើយ ដែលទាមទារឱ្យមានការបន្តយកចិត្តទុកដាក់បន្ថែមទៀតពីសំណាក់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងអស់ ទាំងក្នុងតំបន់ និងទូទាំងពិភពលោក។

ក្រោមប្រធានបទ "**សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍**" យើងផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើសហគមន៍ ដោយសហគមន៍ជាអ្នកដែលរស់នៅជាមួយនឹងហានិភ័យ ឬរង

ផលប៉ះពាល់ដោយមេរោគអេដស៍។ សហគមន៍ ជាអ្នកឈរជួរមុខនៃវឌ្ឍនភាព ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយភ្ជាប់មនុស្សជាមួយនឹងសេវាសុខភាពសាធារណៈ បង្កើតការជឿទុកចិត្តក្នុងការតាមដានការអនុវត្តគោលនយោបាយ និងសេវាកម្ម ផ្តល់សេវានានាប្រកបដោយគុណភាព។ ជាមួយគ្នានេះ យើងគួរផ្តល់នូវគំនិតផ្តួចផ្តើមលើតម្រូវការសម្រាប់សកម្មភាពរួម និងកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយអំពាវនាវឱ្យមានការទទួលខុសត្រូវរួមគ្នាប្រកបដោយតម្លាភាពក្នុងការបែងចែក និងការប្រើប្រាស់ធនធាន ក៏ដូចជាការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់អ្នករស់នៅ ឬរងផលប៉ះពាល់ដោយសារជំងឺនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានញ្ជាក់ជូនថា ការដឹកនាំដោយសហគមន៍ អាចបន្ថែមកម្លាំងកាន់តែរឹងមាំដល់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ជាសកល ក្នុងនោះ យើងជំរុញឱ្យមាន វឌ្ឍនភាពឆ្ពោះទៅរកការបិទបញ្ចប់ជំងឺអេដស៍ក្នុងពេលខាងមុខ។ ដូច្នេះ សូមអំពាវនាវឱ្យមានការធ្វើសកម្មភាពនានាក្នុងគោលដៅគាំទ្រសហគមន៍ដោយភ្ជាប់ជាមួយតួនាទីដឹកនាំរបស់ពួកគេ ក្នុងការបញ្ចេញនូវសក្តានុពលពេញលេញ ដើម្បីដឹកនាំសហគមន៍។

ក្នុងតួនាទីភាពជាអ្នកដឹកនាំរបស់សហគមន៍ គេចាំបាច់ត្រូវដើរតួនាទីស្នូលនៅក្នុងការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ៖ រៀបចំថវិកា ការអនុវត្ត និងការត្រួតពិនិត្យ និងការវាយតម្លៃ។ ការដាក់ចេញនូវវិធានការនានា រួមជាមួយបទប្បញ្ញត្តិទាំងឡាយ គឺជាការចាំបាច់ ដែលសម្របសម្រួលតួនាទីរបស់សហគមន៍ ក្នុងការផ្តល់សេវា ធានាលំហសង្គមស៊ីវិល និងការពារសិទ្ធិមនុស្ស ដើម្បីជំរុញការឆ្លើយតបមេរោគអេដស៍ជាសកល ហើយយើងនឹងមើលឃើញ និងមានសុទិដ្ឋិនិយមចំពោះសហគមន៍ដែលកំពុងឈានមុខគេក្នុងទិវាប្រយុទ្ធនឹងជំងឺអេដស៍ នៅទូទាំងពិភពលោក។

ក្រោយពីបានសម្រេចនូវគោលដៅ៩០-៩០-៩០ មុនកាលកំណត់ នៅឆ្នាំ២០១៧ កម្ពុជាបានបន្តប្តេជ្ញាចិត្តប្រកបដោយមហិច្ឆតា ក្នុងការលុបបំបាត់ការឆ្លងរីករាលដាលនឹងមេរោគអេដស៍នៅឆ្នាំ២០២៥ គឺមុនគោលដៅពិភពលោក៥ឆ្នាំ ដែលក្នុងនោះ យើងត្រូវធ្វើឱ្យសម្រេចគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ និងមិនទុកនរណាម្នាក់ចោលដោយមិនបានទទួលការយកចិត្តទុកដាក់ឡើយ។ យើងមានក្តីសង្ឃឹមយ៉ាងមុតមាំថា នឹងកសាងមនុស្សជាតិជំនាន់ថ្មីមួយដែលគ្មានអេដស៍។

ទោះបីយ៉ាងណា ការឆ្លងរាលដាលថ្មីនៃមេរោគអេដស៍នៅមិនទាន់អាចជៀសផុតបានទាំងស្រុងនៅឡើយ។ កំណើននៃការឆ្លងថ្មីនៅតែជាផ្នែកមួយនៃឧបសគ្គ ដែលកំពុងរារាំងវឌ្ឍនភាពក្នុងការឈានទៅបិទបញ្ចប់ជំងឺអេដស៍ ដែលជំរុញឱ្យមានការចូលរួមដោះស្រាយរួមគ្នា ទាំងក្នុងតំបន់ និងទូទាំងពិភពលោកផងដែរ។ យើងទាំងអស់គ្នាត្រូវធ្វើសកម្មភាពជាក់ស្តែងដែលចាំបាច់ ដោយបង្កើនភាពអាចរកបានប្រកបដោយគុណភាពនៃសេវាកម្មនានា ក្នុងការផ្តល់ប្រឹក្សា ការធ្វើតេស្ត ការថែទាំព្យាបាល សម្រាប់អ្នកជំងឺអេដស៍គ្រប់ៗគ្នាដោយមិនប្រកាន់ពូជសាសន៍ ឬពណ៌សម្បុរឡើយ។ កំណែទម្រង់ច្បាប់ គោលនយោបាយ បទអន្តរាគមន៍ និងការអនុវត្តវិធានផ្សេងៗ ដើម្បីដោះស្រាយការមាក់ងាយ និងរើសអើងអ្នកជំងឺអេដស៍ នឹងត្រូវបានទទួលការគាំទ្រយ៉ាងខ្លាំងក្លាពីសហគមន៍។

ជាការពិត ការបញ្ចប់ជំងឺអេដស៍អាចសម្រេចទៅបានលុះត្រាតែយើងរួមគ្នាដោះស្រាយ។ ក្នុងនោះ មេដឹកនាំពិភពលោកត្រូវតែធ្វើសកម្មភាពដោយភាពក្លាហាន និងការទទួលខុសត្រូវ ជាមួយគ្នានេះ

យើងទាំងអស់គ្នា នៅគ្រប់ទីកន្លែង ត្រូវតែខិតខំឱ្យអស់ពីសមត្ថភាព ដើម្បីជួយដោះស្រាយបញ្ហាប្រឈម ដែលសកម្មភាពទាំងនេះនឹងត្រូវបានដឹកនាំដោយស្ថាប័នជាតិ និងដោយសហគមន៍ផងដែរ។

នាឱកាសដ៏វិសេសវិសាលនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជម្រាបជូនអង្គពិធីទាំងមូល នូវស្ថានភាពនៃការរីករាលដាល និងសមិទ្ធផលនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍មួយចំនួនដូចតទៅ៖

- យោងតាមប្រភពទិន្នន័យសង្ខេបឆ្នាំ២០២២ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការUNAIDS បានឱ្យដឹងថា ចំនួនប៉ាន់ស្មានអ្នកផ្ទុកមេរោគអេដស៍ សរុបមានប្រមាណ ៧៦.០០០នាក់។ ក្នុងនោះ អ្នកមកធ្វើតេស្តឈាម និងបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនមានចំនួន ៦៧.៣៨៣នាក់ ស្មើនឹងប្រមាណ៨៦%។ ជាមួយគ្នានេះ ៩៩% នៃអ្នកផ្ទុកមេរោគអេដស៍ ដែលបានដឹងពីស្ថានភាពរបស់ខ្លួន បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។ ហើយ៩៨%នៃអ្នកដែលបានទទួលការព្យាបាល ត្រូវបានពិនិត្យឃើញថាមានការកាត់បន្ថយចំនួនមេរោគមកនៅកម្រិតទាបបំផុត។ ភាពរឹងមាំច្បាស់លាស់ នៃការឆ្លើយតបនឹងមេរោគអេដស៍នៅកម្ពុជា បានបញ្ជាក់អំពីសមត្ថភាពនៃការបញ្ចូលអ្នកផ្ទុកមេរោគអេដស៍ឱ្យទៅទទួលសេវាព្យាបាល ពេលបានធ្វើរោគវិនិច្ឆ័យរួច និងរក្សាទុកឱ្យនៅព្យាបាល ព្រមទាំងលទ្ធភាពបង្កើនប្រសិទ្ធភាពនៃការព្យាបាលជាអតិបរមា។
- អត្រាប្រេវ៉ាឡង់អ្នកផ្ទុកមេរោគអេដស៍ពី១៥ទៅ៤៩ឆ្នាំ មានចំនួន0.៦ %។
- ចំនួនប៉ាន់ស្មាននៃអ្នកឆ្លងថ្មី មាន ១.៤០០នាក់ (មានការកើនឡើង ៣០០នាក់ បើប្រៀបធៀបនឹងតួលេខក្នុងឆ្នាំកន្លងទៅ ដែលមានត្រឹមតែ ១.១០០នាក់ប៉ុណ្ណោះ) និងអ្នកស្លាប់មានចំនួន ១.១០០នាក់ ( ឬមានមនុស្ស៤នាក់បានឆ្លងថ្មីក្នុង១ថ្ងៃ និងមានមនុស្សស្លាប់ដោយសារជំងឺអេដស៍ ៣នាក់ក្នុង១ថ្ងៃ)។
- ការវិភាគក៏បានបង្ហាញថា កំណើននៃការឆ្លងមេរោគអេដស៍ថ្មី គឺស្ថិតក្នុងចំណោមបុរស និងក្មេងប្រុស មានចំនួន៧៩% ហើយ៨៣% នៃអ្នកឆ្លងថ្មី គឺជាក្រុមប្រឈម ឬជាក្រុមប្រជាជនគន្លឹះ។
- ការរាយការណ៍ពីការមាក់ងាយ និងរើសអើងពីខាងក្រៅមានការធ្លាក់ចុះ ជាពិសេសការបដិសេធមិនផ្តល់ការងារប្រមាណពី៤៦%នៅឆ្នាំ២០១០ មកនៅតែប្រមាណ២% នៅឆ្នាំ២០១៩ និងការបំពានជាពាក្យសម្ដីប្រមាណពី១៤%នៅឆ្នាំ២០១០ មកនៅតែប្រមាណ២% នៅឆ្នាំ២០១៩។ ប៉ុន្តែការមាក់ងាយ និងរើសអើងដោយខ្លួនឯង ជាពិសេសអារម្មណ៍ខ្មាសអៀន នៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភនៅឡើយដោយមានអត្រា៧១.៥% នៅឆ្នាំ២០១០ មកនៅ៦២.៧% នៅឆ្នាំ២០១៩ (Stigma Index 2.0, 2019)។

ក្នុងគោលបំណងឱ្យការធ្វើអន្តរាគមន៍ទាំងឡាយបានទទួលជោគជ័យ និងធានាចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងរយៈពេលវែង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់មួយចំនួនជាអាទិ៍៖

- សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីបង្កើតនិយាមបែបបទដាក់សំណុំសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ផែនការវិនិយោគឃុំ សង្កាត់ និងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដើម្បីឃុំ សង្កាត់មានលទ្ធភាពជួយស្វែងរកករណីផ្ទុកមេរោគអេដស៍ បញ្ជូនទៅរកសេវាថែទាំព្យាបាល សម្របសម្រួលបង្កបរិយាកាសអំណោយផល និងផ្តល់ការគាំទ្រសង្គមដល់គ្រួសារអ្នកជំងឺអេដស៍ក្រីក្រ។
- សហការជាមួយក្រសួងផែនការ ផ្តល់អត្តសញ្ញាណកម្មគ្រួសារក្រីក្រជូនដល់អ្នកផ្ទុកមេរោគអេដស៍ក្រីក្រ ដើម្បីទទួលបានអត្ថប្រយោជន៍បន្ថែមក្នុងការថែទាំសុខភាព និងការគាំទ្រសង្គម។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងឡាយ បន្តជំរុញការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធ និងបង្កើនការអប់រំបង្ការការចម្លងមេរោគអេដស៍ ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់ ក្រុមយុវវ័យ បុគ្គលិកសហគ្រាសគ្រឹះស្ថាននានា ពលរដ្ឋចំណាកស្រុក និងវិស័យទេសចរណ៍។
- ធានាឱ្យបាននូវចីរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើការបញ្ជ្រាប និងបញ្ចូលបញ្ហាអេដស៍ទៅក្នុងផែនការរួមរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- បន្តធានា និងកំណត់ក្រុមគោលដៅ និងក្រុមប្រជាជនប្រឈមមុខខ្ពស់ និងអ្នកផ្ទុកមេរោគអេដស៍ជាអាទិភាពដែលត្រូវផ្តល់សិទ្ធិ និងឱកាសទទួលបានសេវាសុខភាព និងសេវាសង្គម ដូចគ្នានឹងប្រជាជនទូទៅនៅក្នុងសង្គម។

ជាមួយនោះ រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា កន្លងទៅ បានបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីតាក់តែងគោលនយោបាយលុបបំបាត់អេដស៍ និងចីរភាពកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨ ក្នុងបំណងលុបបំបាត់អេដស៍នៅឆ្នាំ២០២៥ខាងមុខ និងធានាថាមេរោគអេដស៍នឹងមិនវិលជាបង្កជាគ្រោះថ្នាក់ដល់សុខភាពសាធារណៈផ្សេងទៀត នៅពេលដែលកម្ពុជាឈប់ទទួលហិរញ្ញវត្ថុពីប្រភពខាងក្រៅ។

គោលនយោបាយនោះ មាន៧ចំណុចគឺ ៖

១) គោលនយោបាយទី១ ៖ ពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍

២) គោលនយោបាយទី២ ៖ ពន្លឿនអត្រាគ្របដណ្តប់កម្មវិធីបង្ការឱ្យបានលើសពី៩៥%

៣) គោលនយោបាយទី៣ ៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីថែទាំព្យាបាល

៤) គោលនយោបាយទី៤ ៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីគាំពារសង្គម

៥) គោលនយោបាយទី៥ ៖ បញ្ចប់ការរើសអើង និងមាក់ងាយ

៦) គោលនយោបាយទី៦ ៖ ចលនាធនធាន

៧) គោលនយោបាយទី៧ ៖ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធតាមដាន និងវាយតម្លៃជាតិ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កំពុងដឹកនាំតាក់តែងគោលនយោបាយ ដែលរាជរដ្ឋាភិបាលអាចនឹងអនុម័តនៅដើមនីតិកាលទី៧នៃរដ្ឋសភានេះ ហើយសមាសធាតុគន្លឹះ៣ដែលជាសមិទ្ធផលក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលកម្ពុជា បាន និងកំពុងធ្វើឱ្យសម្រេចជោគជ័យមកទល់ពេល

នេះ រួមមាន : ១) មគ្គុទ្ទេសភាព និងភាពជាម្ចាស់ ២) ភាពជាដៃគូ និង ៣) ការវិនិយោគ។ ក្នុងមគ្គុទ្ទេសក៍ភាព និងភាពជាម្ចាស់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដឹកនាំយន្តការសម្របសម្រួល និងឆ្លើយតបជាពហុវិស័យ។ ជាមួយគ្នានេះរាជរដ្ឋាភិបាល កម្ពុជាក៏បានដាក់ចេញនូវវិធានការ៦ចំណុច ដើម្បីធានាចីរភាពក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ កាលពីខែកុម្ភៈ ឆ្នាំ២០១៩នេះផងដែរ ពាក់ព័ន្ធនឹងកម្មវិធីមូលនិធិសកល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានទទួលតួនាទីជាអ្នកទទួលជំនួយផ្ទាល់ ចាប់តាំងពីខែមេសា ឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ននេះ ក្នុងភាពជាដៃគូ។ ដៃគូអភិវឌ្ឍន៍ដូចជា UNAIDS UNDP អង្គការសុខភាពពិភពលោក អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល បានធ្វើការរួមគ្នាដោយត្រួតពិនិត្យនូវវឌ្ឍនភាពនៃការអនុវត្តកម្មវិធីអេដស៍។ ក្នុងការវិនិយោគ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនការផ្តល់ថវិកា និងការចូលរួមយ៉ាងសកម្មក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ក្នុងឱកាសដ៏វិសេសវិសាលនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានអំពាវនាវឱ្យមានការគាំទ្របន្ថែមទៀតពីរាជរដ្ឋាភិបាល កាកបាទក្រហមកម្ពុជា និងដៃគូអភិវឌ្ឍន៍ទាំងអស់។ ក្នុងនោះ សូមបន្តជួយបង្កើនការគាំទ្រទាំងហិរញ្ញវត្ថុ និងទាំងបច្ចេកទេស ដើម្បីឱ្យយើងមានលទ្ធភាពរក្សាចីរភាព និងត្រៀមអនុវត្តផែនការយុទ្ធសាស្ត្រជាតិលើកទី៦ ឆ្នាំ២០២៤-២០២៨ ឆ្ពោះទៅលុបបំបាត់ការឆ្លងរីករាលដាលមេរោគអេដស៍ប្រកបដោយជោគជ័យ។ ជាមួយគ្នានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ សូមចូលរួម ប្តេជ្ញាចិត្តដ៏មោះមុតជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដូចខាងក្រោម ៖

- សូមយុវវ័យទាំងអស់កុំឆាប់ប្រឡូកនឹងការរួមភេទ ហើយត្រូវចាកចេញឱ្យឆ្ងាយពីគ្រឿងញៀនដែលជាកត្តាប្រឈមខ្ពស់នឹងការឆ្លងមេរោគអេដស៍។
- សូមស្ត្រីមានផ្ទៃពោះទាំងអស់ទៅទទួលយកការធ្វើតេស្តឈាមរកមេរោគអេដស៍។ បើមានលទ្ធផលវិជ្ជមាន ត្រូវប្រញាប់ស្វែងរកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យបានឆាប់រហ័សនៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យរដ្ឋនានា នៅទូទាំងប្រទេស។
- សូមអ្នកដែលមានការប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ ប្រញាប់ទៅស្វែងរកការធ្វើតេស្តឈាមរកមេរោគអេដស៍ឱ្យបានឆាប់រហ័សនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ ឬបណ្តាញអង្គការសង្គមស៊ីវិល ដើម្បីឈានទៅទទួលបានសេវាថែទាំព្យាបាលទាន់ពេលវេលា។
- សូមអ្នកដឹងថាមានផ្ទុកមេរោគអេដស៍ទាំងអស់ ប្រញាប់ទៅទទួលការថែទាំព្យាបាលឱ្យបានឆាប់រហ័ស និងគោរពវេជ្ជបញ្ជាឱ្យបានខ្ជាប់ខ្ជួន ដើម្បីការពារការស្រុតចុះសុខភាព និងចៀសវាងការកើតនូវភាពស៊ាំរបស់មេរោគទៅនឹងឱសថប្រឆាំងមេរោគអេដស៍ ជាមូលហេតុនៃមរណភាពដោយសារជំងឺអេដស៍ និងសូមកុំបន្តចម្លងមេរោគអេដស៍ដល់អ្នកដទៃទៀត។
- សូមចាត់ទុកអ្នកផ្ទុកមេរោគអេដស៍ជាជនរងគ្រោះ ដែលត្រូវចូលរួមលុបបំបាត់រាល់ទម្រង់នៃការរើសអើង និងមាក់ងាយចំពោះពួកគាត់ និងត្រូវផ្តល់ការគាំទ្រគ្រប់លទ្ធភាព។
- រាល់ការឆ្លើយតបនឹងមេរោគអេដស៍ និងអ្នកជំងឺអេដស៍ទាំងអស់ ត្រូវតែឈរលើគោលការណ៍សមធម៌ សមភាព និងសិទ្ធិមនុស្ស។

តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ដែល

តែងតែផ្តល់ការគាំទ្រជានយោបាយ និងយុទ្ធសាស្ត្រ ដល់ការឆ្លើយតបនឹងការរីករាលដាលមេរោគអេដស៍។ ជាពិសេស ការចូលរួមដ៏សកម្ម និងមិនចេះនឿយហត់របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ក្នុងការផ្តល់ការគាំទ្រជាប់ជាប្រចាំ ទាំងថវិកា សម្ភារ និងស្មារតី ជួយដល់ប្រជាពលរដ្ឋក្រីក្រ អ្នករងគ្រោះទូទៅ ដោយឡែកប្រជាពលរដ្ឋដែលកំពុងរងគ្រោះដោយផ្ទាល់ និងដោយប្រយោលពីការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍នៅទូទាំងប្រទេស។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី មូលនិធិសកលអង្គការសង្គមស៊ីវិល ផ្នែកឯកជន សិល្បករ សិល្បការិនីដែលជាទូតសុច្ឆន្ទៈសម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ បណ្តាញអ្នកផ្ទុកមេរោគអេដស៍ ក្រុមប្រជាជនគន្លឹះ និងក្មួយៗជាយុវវ័យទាំងអស់ ព្រមទាំងប្រជាពលរដ្ឋទូទៅដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការសម្រេចបាននូវសមិទ្ធផលជាទីមោទនៈជូនប្រទេសកម្ពុជា នាពេលនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានបួងសួងទេវតាសូមប្រទានពរជ័យមហាប្រសើរជូនឯកឧត្តម **ទេវ៉ា ឆិស៊ុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត ពេជ ចន្ទ មុន្នី ហ៊ុនម៉ាណែត** សូមមានសុខភាពល្អបរិបូណ៌ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីបន្តចូលរួមចំណែកដឹកនាំកម្ពុជាឱ្យចាកផុតពីគ្រោះគំរាមកំហែងដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ក្រោមមាគ៌ាដឹកនាំប្រកបដោយគតិបណ្ឌិត របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាង ដៃគូអភិវឌ្ឍន៍ តំណាងអង្គទូត ភ្ញៀវជាតិ អន្តរជាតិ និងក្មួយៗទាំងអស់ សូមប្រកបនូវពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

៣.៦. បន្ទាប់មកទៀតជាសុន្ទរកថា និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ទេវ៉ា ឆិស៊ុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ៖**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានទទួលបុព្វសិទ្ធិជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២៣ លើកទី៣០ នៅកម្ពុជា ក្រោមប្រធានបទ “**សហគមន៍តែមួយដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍**” នាពេលនេះ។ ក្នុងនាម **សម្តេចធិបតីនាយករដ្ឋមន្ត្រី** សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូន ចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធាន**

**កាកបាទក្រហមកម្ពុជា** ដែល **សម្តេច** ក្នុងឋានៈជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា តែងតែដឹកនាំ និងចូលរួមដោយផ្ទាល់ក្នុងការពង្រឹងបណ្តាញកាកបាទក្រហមគ្រប់លំដាប់ថ្នាក់នៅទូទាំងប្រទេស ក្នុងការប្រឆាំងនឹងការរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍ ជាពិសេស បានរួមចំណែកទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាពមួយកម្រិតបន្ថែមទៀត។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានពាំនាំមកជូននូវការវាយតម្លៃខ្ពស់ ពី **សម្តេចធិបតី** និង **លោកជំទាវបណ្ឌិត** ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមការដឹកនាំរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ដែលបានខិតខំសម្រេចនូវសមិទ្ធផលធំៗជាច្រើន ក្នុងការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ជាពិសេស ក្នុងស្ថានភាពដែលកម្ពុជា និងពិភពលោកបានជួបប្រទះនូវវិបត្តិកូវីដ-១៩ ក្នុងរយៈពេលកន្លងទៅ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស បងប្អូនជនរួមជាតិយើង ដែលបានចូលរួមគាំទ្រ និងខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីប្រកបដោយឆន្ទៈមោះមុត និងការប្តេជ្ញាខ្ពស់ សម្រេចបាននូវលទ្ធផលជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈក្នុងការប្រយុទ្ធប្រឆាំងជំងឺអេដស៍។ យើងជឿជាក់ថាយើងនឹងសម្រេចបាននូវ **គោលដៅសូន្យបី** និងគោលដៅ **៩៥-៩៥-៩៥ នាឆ្នាំ២០២៥** ខាងមុខនេះ។

តាមរយៈសារលិខិតរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងរបាយការណ៍របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ព្រមទាំងចំណាប់អារម្មណ៍របស់**លោកស្រី Patricia Ongpin** នាយិកាអង្គការUNAIDS ប្រចាំប្រទេសកម្ពុជា ឡាវ និងម៉ាឡេស៊ី តំណាងគណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព (HACC) ក៏ដូចជាចំណាប់អារម្មណ៍របស់តំណាងបងប្អូនគ្រួសាររងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍ មុននេះ យើងអាចជឿជាក់បានថា គោលដៅរបស់យើងក្នុងការកសាងសង្គមមួយដែលគ្មានការគំរាមកំហែងពីមេរោគអេដស៍ និងជំងឺអេដស៍នឹងអាចសម្រេចបានប្រកបដោយជោគជ័យ។

កម្ពុជាកំពុងតែស្ថិតនៅលើវិថីមួយ ដែលកំពុងឈានទៅសម្រេចបាននូវ "**គោលដៅ៩៥-៩៥-៩៥**" នៅត្រឹមឆ្នាំ២០២៥ ពោលគឺ **៩៥%** នៃអ្នកផ្ទុកមេរោគអេដស៍ បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន **៩៥%** នៃអ្នកដែលដឹងស្ថានភាពផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង **៩៥%** នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួន ដែលបានកំណត់ដោយអង្គការសហប្រជាជាតិនៅត្រឹម

ឆ្នាំ២០៣០។ ជាក់ស្តែង នៅក្នុងរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២៣ ក៏បានបង្ហាញថា កម្ពុជាបានកាត់បន្ថយការចម្លងថ្មីនៃមេរោគអេដស៍ ពី**២.០០០នាក់** ក្នុងឆ្នាំ២០១០ មកត្រឹមចំនួនប៉ាន់ស្មានប្រហែល **១.៤០០នាក់** ក្នុងឆ្នាំ២០២២។ នៅត្រីមាសទី៣ ឆ្នាំ២០២៣នេះ អ្នកផ្ទុកមេរោគអេដស៍ចំនួន **៦៧.០៨០នាក់** ប្រមាណ៩៩%នៃអ្នកដែលបានដឹងស្ថានភាពផ្ទុកមេរោគអេដស៍ បានទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដោយឥតគិតថ្លៃពីមន្ទីរពេទ្យរដ្ឋ ដែលបានធ្វើឱ្យអត្រាមរណភាពដោយសារជំងឺអេដស៍បន្តធ្លាក់ចុះជារៀងរាល់ឆ្នាំ។ ការឆ្លងមេរោគអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនដោយការចាក់ម្ជុលមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ពីអត្រាប្រមាណ២៤,៨% នៅឆ្នាំ២០១២ មកនៅអត្រាប្រមាណ ១៥,២% ក្នុងឆ្នាំ២០១៧។ សន្ទស្សន៍នៃការរើសអើងមាក់ងាយអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ មានការថយចុះខ្លាំងគួរជាទីមោទនៈ។

ទោះជាយ៉ាងនេះក្តីប្រសិនបើយើងភ្លេចខ្លួន និងធ្វេសប្រហែសការឆ្លងរាលដាលមេរោគអេដស៍នឹងអាចផ្ទុះឡើងវិញ ដែលពិបាកនឹងគ្រប់គ្រងជាងមុនទៅទៀត ជាពិសេសការផ្ទុះឡើងនៅក្នុងចំណោមប្រជាជនប្រឈមមុខខ្ពស់ រួមមានក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមស្ត្រីបម្រើការងារក្នុងកន្លែងកម្សាន្តសប្បាយ ក្រុមយុវវ័យ ក្រុមអ្នកប្រើប្រាស់ និងចាក់គ្រឿងញៀនជាដើម។ ជាមួយគ្នានេះ អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានប្រមាណ៩,៩% ក្នុងឆ្នាំ២០២២ ដែលជាអត្រាខ្ពស់មួយដែលត្រូវយកចិត្តទុកដាក់។ ការឆ្លងមេរោគអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនទូទៅមានអត្រា៤% នៅឆ្នាំ២០១២ និងអត្រាប្រមាណ ៥,៧% ក្នុងឆ្នាំ២០១៧។ នៅក្នុងស្ថានភាពនេះ សូមក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញប្រជាជនគន្លឹះវ័យក្មេង បន្តការយកចិត្តទុកដាក់ឱ្យបានខ្ពស់ និងចូលរួមឱ្យបានកាន់តែសកម្មថែមទៀតជាមួយរាជរដ្ឋាភិបាល ដើម្បីបញ្ចៀសហានិភ័យខាងលើឱ្យមានប្រសិទ្ធភាព និងទាន់ពេល ក្នុងដំណើរឆ្ពោះទៅបញ្ចប់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នាឆ្នាំ២០២៥។

ពិតណាស់ ក្នុងដំណើរឆ្ពោះទៅសម្រេចគោលដៅលុបបំបាត់ជំងឺអេដស៍ ប្រកបដោយនិរន្តរភាព និងចីរភាព ពិតជាមានការលំបាក និងស្មុគស្មាញ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** យល់ថា កម្ពុជានៅតែអាចសម្រេចគោលដៅនេះបាន តាមរយៈការដឹកនាំ ការគ្រប់គ្រង ការសម្របសម្រួល និងការចូលរួមពីគ្រប់សមាសភាពសង្គម តាមរយៈការខិតខំជម្នះឱ្យបាននូវរាល់ឧបសគ្គនានា ដែលអាចកើតមានឡើង ដូចជា ៖ កត្តារើសអើង កត្តាធនធាន នវានុវត្តន៍ និងបរិយាបន្នជាដើម។ ជាក់ស្តែង នៅឆ្នាំ២០១៧ អង្គការ UNAIDS បានប្រកាសទទួលស្គាល់ប្រទេសកម្ពុជាក្នុងចំណោមប្រទេសចំនួន៧ ទៀតក្នុងពិភពលោក ជាប្រទេសដែលអាចសម្រេចបាននូវគោលដៅ ៩០-៩០-៩០ មុនកាលកំណត់។ បន្ថែមពីនេះ ផែនការយុទ្ធសាស្ត្រជាតិទូលំ

ទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ ត្រូវបាន អនុវត្តប្រកបដោយជោគជ័យ ផ្អែកលើសសរស្តម្ភទាំងបី រួមមាន ១).ការដឹកនាំ និងភាពជាម្ចាស់, ២).ភាព ជាដៃគូ និង៣).ការវិនិយោគ។ ជាមួយគ្នានេះ ឆ្នាំ២០២៣នេះ គឺជាឆ្នាំចុងក្រោយនៃការអនុវត្តផែនការយុទ្ធ សាស្ត្រនេះ ដូចនេះយើងត្រូវពិនិត្យឡើងវិញ (Review) នូវសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ យើង ថ្លឹងថ្លែងឡើងវិញ (Rebalance) អំពីបញ្ហាប្រឈម ឬហានិភ័យនិងឱកាស និងការកែសម្រួល ឡើងវិញ (Recalibrate) នូវសកម្មភាពអាទិភាពថ្មីៗដែលយើងនឹងត្រូវអនុវត្តក្នុងរយៈពេល៥ឆ្នាំខាងមុខ ជាពិសេសសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបនឹងមេរោគ អេដស៍ និងជំងឺអេដស៍លើកទី៦។

ឆ្លៀតក្នុងឱកាសចូលរួមអបអរសាទរទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៣នេះ ក្នុងនាម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សូមចែករំលែកនូវទស្សនៈមួយចំនួនក្នុងការលុបបំបាត់អេដស៍នៅកម្ពុជា ដូចតទៅ ៖

ទី១- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តដឹកនាំ និងសម្របសម្រួលជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ ក្នុងការរៀបចំគោលនយោបាយលុបបំបាត់ជំងឺអេដស៍ នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ឱ្យបានទាន់ពេល ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី6 តាមប្រព័ន្ធជាតិប្រកបដោយនិរន្តរភាព និងចីរភាព។

ទី២- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវបន្តអនុវត្តដោយម៉ឺងម៉ាត់ នូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដើម្បីជានាភាពជោគជ័យ និងនិរន្តរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ សំដៅឈានទៅបញ្ចប់ជំងឺអេដស៍នៅឆ្នាំ ២០២៥នៅកម្ពុជា។

ទី៣- អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវវិធានការទាំង៦ ទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ទី៤- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តសហការជាមួយក្រសួងសុខាភិបាល ធ្វើការសិក្សារៀបចំយន្តការ និងយុទ្ធសាស្ត្រអន្តរាគមន៍ក្នុងការលុបបំបាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅត្រឹមឆ្នាំ២០២៥ និងត្រូវរិះរកវិធីកាត់បន្ថយបន្ថែមទៀតនូវអត្រាបោះបង់ការព្យាបាល និងអត្រាស្លាប់របស់អ្នកផ្ទុកមេរោគអេដស៍ព្រមទាំងបន្តពង្រឹង និងបង្កើនកិច្ចសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿង

ញៀន ដើម្បីបង្ការ និងទប់ស្កាត់ឱ្យកាន់តែមានប្រសិទ្ធភាពនូវការឆ្លងរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់ និងអ្នកចាក់គ្រឿងញៀន។

**ទី៥-** ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមជំរុញការអប់រំផ្សព្វផ្សាយអំពីមេរោគអេដស៍ និងជំងឺអេដស៍ និងបង្កើតឱ្យមានមធ្យោបាយអប់រំផ្សព្វផ្សាយថ្មីៗដែលមានលក្ខណៈឌីជីថល ដើម្បីបង្ការការចម្លងមេរោគអេដស៍ក្នុងសហគមន៍ ជាពិសេសចំពោះក្រុមប្រជាជនគន្លឹះរួមមាន ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមអ្នកប្រើប្រាស់ និងចាក់គ្រឿងញៀន ក្រុមស្ត្រីបម្រើការងារក្នុងកន្លែងកម្សាន្តសប្បាយ និងក្រុមយុវវ័យទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ឱ្យទទួលបានព័ត៌មានទាន់ពេល និងការយល់ដឹងទូលំទូលាយ ដើម្បីការពារខ្លួនចៀសពីការឆ្លងមេរោគអេដស៍។

**ទី៦-** អភិបាលរាជធានី ខេត្ត ត្រូវបន្តពង្រឹងយន្តការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ឱ្យបានទូទាំងប្រទេស ដើម្បីទទួលខុសត្រូវក្នុងភាពជាម្ចាស់ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព។

**ទី៧-** គ្រប់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការដៃគូអន្តរជាតិ អង្គការជាតិ អង្គការសង្គមស៊ីវិល និងវិស័យឯកជនទាំងអស់ បន្តយន្តការធ្វើការរួមគ្នាស្របតាមអភិក្រម «ជវភាពនៃប្រព័ន្ធតួអង្គតែមួយ»(Dynamics of Stakeholder System) ក្នុងការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន ឆ្ពោះទៅសម្រេចជោគជ័យតាមគោលដៅដែលបានកំណត់។

ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងក្នុងនាម **ឯកឧត្តម** ផ្ទាល់ សូមប្រកាសជាឱឡារិកថា រាជរដ្ឋាភិបាលកម្ពុជានៅតែចាត់ទុកការងារប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា ជាអាទិភាពខ្ពស់មួយ ដូចមានចែងនៅក្នុង **កម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា និងការប្តេជ្ញាចិត្តដ៏មុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលុបបំបាត់អេដស៍នៅឆ្នាំ២០២៥ ជាពិសេសដូចបានចែងក្នុងបញ្ចកោណទី១ នៃយុទ្ធសាស្ត្របញ្ចកោណក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ កសាងសេដ្ឋកិច្ចគ្រួសារ សហគមន៍ និងប្រទេសជាតិឱ្យមានការរីកចម្រើនឈានទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជា។

ក្នុងស្មារតីនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ អង្គការសង្គមស៊ីវិលនានា វិស័យឯកជន សិល្បករ កីឡាករ ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមចូលរួមឱ្យកាន់តែសកម្ម ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់នូវការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា និងសូមអំពាវនាវដល់សហគមន៍អន្តរជាតិ ដៃគូអភិវឌ្ឍនានា

សូមបន្តជួយគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដល់សកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យកម្ពុជាអាចឈានទៅសម្រេចបានតាមគោលដៅលុបបំបាត់អេដស៍ឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២៣-២០២៨ និងឆ្នាំបន្តបន្ទាប់តទៅ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានប្រគេនពរ និងប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្មួយៗយុវជន និងអង្គពិធីទាំងមូល សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសជាឱឡារិកថាកម្ពុជាជា "**សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍**"។

អង្គពិធីបានបញ្ចប់តាមរបៀបវារៈដែលបានគ្រោងទុក នៅថ្ងៃ ខែ ឆ្នាំដដែល ក្រោមបរិយាកាសរីករាយ និងស្និទស្នាលបំផុត៕

ថ្ងៃពុធ ៩រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៣

**អ្នកធ្វើរបាយការណ៍**

ហួត សេរីវឌ្ឍ

**បានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវ**
**អគ្គលេខាធិការ**

**បណ្ឌិត ឈឹម មិនដារ៉េត**

**បានឃើញ និងឯកភាព**
**ប្រធានអង្គប្រជុំ**

**អៀង_មូលី**

CAMBODIAN RED CROSS

APLF

Asia Pacific Leadership Forum on HIV / AIDS and Development

# សារលិខិត

## សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន
## ប្រធានកាកបាទក្រហមកម្ពុជា
## និងជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំ
## តំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា
## ក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ឆ្នាំ ២០២៣
## ក្រោមប្រធានបទ "សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍"

៚៙៚❀៚៙៚

- *សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា*
- *ក្មួយៗយុវជន និង បងប្អូនជនរួមជាតិ ជាទីស្រឡាញ់រាប់អាន !*

ក្នុងនាមកាកបាទក្រហមកម្ពុជា និងក្នុងនាមខ្ញុំជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា ខ្ញុំមានកិត្តិយស សូមចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍លើកទី ៣០ ក្រោមប្រធានបទ "សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍" ដែលមានគោលបំណងទាញការយកចិត្តទុកដាក់របស់បង-ប្អូនរួមជាតិ ឱ្យបន្តការប្រុងប្រយ័ត្នក្នុងការបង្ការទប់ស្កាត់ការចម្លងមេរោគអេដស៍ និងក្នុងការខិតខំប្រឹងប្រែងអភិវឌ្ឍប្រទេស ដើម្បីកសាងសង្គមជាតិមួយ ដែលពុំមានការគំរាមកំហែងពីមេរោគអេដស៍/ជំងឺអេដស៍។

ក្នុងឱកាសដ៏មានអត្ថន័យនេះ ខ្ញុំសូមចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលកន្លងមកក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងបច្ចុប្បន្នបន្តដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលតែងតែប្តេជ្ញាចិត្តយ៉ាងមោះមុត ក្នុងការដឹកនាំបំផុសចលនាចូលរួមជាចរន្តជាតិតែមួយក្នុងការទប់ស្កាត់ការចម្លងមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យទទួលបានជោគជ័យជាបន្តបន្ទាប់ និងមានការទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ អន្តរជាតិ ជាពិសេសពីស្ថាប័នអង្គការសហប្រជាជាតិ ថែមទៀតផង។ ជាមួយគ្នានេះ កាកបាទក្រហមកម្ពុជា និងក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិ បានប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាលឆ្ពោះទៅសម្រេចគោលដៅដែលជាមោទនភាពថ្មីមួយទៀត ដែលនោះ គឺជាការឈានទៅបញ្ចប់ជំងឺអេដស៍នៅឆ្នាំ ២០២៥។

ប្រធានបទ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ ២០២៣ "សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍" បានគូសបញ្ជាក់យ៉ាងច្បាស់ថា ដើម្បីអាចបញ្ចប់ជំងឺអេដស៍បាន គឺ ទាមទារឱ្យមានការចូលរួមឱ្យបានពេញលេញ និងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដូចដែលព្រះរាជាណាចក្រកម្ពុជាយើង ធ្លាប់បាននិងកំពុងបន្តអនុវត្ត ក្នុងការឆ្លើយតបទូលំទូលាយ និងពហុវិស័យ ទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ ដោយមិនទុកនរណាម្នាក់ឱ្យនៅឯកោឡើយ និងការបង្កើតឱ្យមានមធ្យោបាយអប់រំផ្សព្វផ្សាយថ្មីៗដែលមានលក្ខណៈឌីជីថល។

ជាក់ស្តែង, ក្នុងនាមជាជំនួយការឱ្យអាជ្ញាធរសាធារណៈក្នុងវិស័យមនុស្សធម៌ កាកបាទក្រហមកម្ពុជារួមជាមួយនឹងក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិនៅទូទាំងប្រទេស បាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការ


ឡូត៍ ១៦A ផ្លូវលេខ៦៥២ កែង២៧១ អូរបែកក្អម សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Lot: 16A, Street 652@271, O Bek Kaam, Sangkat Toek Laak 3, Khan Tuol Kork, Phnom Penh, Kingdom of Cambodia
Tel: (855-23)881 511, Fax: (855-23)881 522, P.O. Box: 69, Web: www.redcross.org.kh, Facebook: www.facebook.com/crcnhq, Email: info@redcross.org.kh, crc_adm@online.com.kh

អនុវត្តគោលនយោបាយ និងយុទ្ធសាស្រ្តជាតិបញ្ចប់ជំងឺអេដស៍ តាមរយៈការអប់រំផ្សព្វផ្សាយជាប្រចាំ, ការចុះប្រាស្រ័យទាក់ទងផ្ទាល់, ការផ្តល់ចំណេះដឹងតាមបណ្តាញសង្គម ដោយផ្តោតទៅលើបច្ចុប្បន្នភាពចំណេះដឹងពីស្ថានភាពមេរោគអេដស៍/ជំងឺអេដស៍, បញ្ហាប្រឈម, វិធានការបង្ការការចម្លងមេរោគអេដស៍, វិធានការស្វែងរកសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តរកមេរោគអេដស៍ឱ្យបានទាន់ពេលវេលា, វិធានការស្វែងរកសេវាថែទាំនិងព្យាបាល និងវិធានការស្វែងរកការគាំទ្រ។ លើសពីនេះទៀត, ភាគបាទក្រហមកម្ពុជាបានកំណត់នូវអាទិភាពខ្ពស់ក្នុងការចូលរួមបញ្ចប់ការរើសអើងនិងមាក់ងាយទៅលើអ្នកផ្ទុកមេរោគអេដស៍និងជំងឺអេដស៍, កំពុងលើកទឹកចិត្ត និងគាំទ្រឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់សហគមន៍, ពីអ្នករងគ្រោះផ្ទាល់, ជាពិសេសក្រុមប្រជាជនគន្លឹះ រួមគ្នាជាធ្លុងមួយជាមួយរាជរដ្ឋាភិបាល ចាប់តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ឱ្យចូលរួមឆ្លើយតបនៅក្នុងចរន្តជាតិតែមួយ។

អាស្រ័យហេតុនេះហើយ ក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ឆ្នាំ ២០២៣ ក្រោមប្រធានបទ "សហគមន៍តែមួយ ដឹកនាំឆ្ពោះទៅបញ្ចប់ជំងឺអេដស៍" តាមរយៈសារលិខិតនេះ ខ្ញុំសូមផ្ញើសារសំខាន់ៗ ជូនបង-ប្អូនជនរួមជាតិ ជាពិសេសយុវជនយើង ដូចតទៅ៖

១- ត្រូវប្តេជ្ញាចិត្តចូលរួមទប់ស្កាត់ការរីករាលដាល និងបញ្ចប់ជំងឺអេដស៍ នៅឆ្នាំ២០២៥ ដោយប្រកាន់ខ្ជាប់គោលការណ៍សមភាព និងបរិយាបន្ន

២- ត្រូវនាំគ្នា អនុវត្តវិធីសាស្រ្ត មិត្ត-អប់រំ-មិត្ត ក្នុងការចាកឆ្ងាយពីគ្រឿងញៀន ភាពភ្លើតភ្លើនផ្លូវភេទដែលជាហានិភ័យខ្ពស់នៃការឆ្លងមេរោគអេដស៍/ជំងឺកាមរោគផ្សេងៗ និងត្រូវខិតខំរៀនសូត្រ ថែរក្សាសុខភាព បរិភោគអាហារូបត្ថម្ភល្អដូចពាក្យចាស់ពោលថា "ស្រឡាញ់ខ្លួន ឱ្យស្ងួនចំណី"

៣- សូមបង-ប្អូនរួមជាតិ ដែលសង្ស័យថាបានប្រឈមនឹងមេរោគអេដស៍ ត្រូវស្វែងរកសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តរកមេរោគអេដស៍ឱ្យបានឆាប់បំផុត, ទទួលបានការថែទាំសុខភាព និងត្រូវប្រើថ្នាំប្រឆាំងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់

៤- សូមស្ត្រីមានផ្ទៃពោះ ទៅពិនិត្យនិងថែទាំផ្ទៃពោះជាមួយឆ្មប ឬគ្រូពេទ្យយ៉ាងហោចឱ្យបាន៤ដងមុនសម្រាលកូន និងទទួលយកសេវាទប់ស្កាត់ការចម្លងមេរោគអេដស៍/ស្វាយ និងថ្លើម ពីសេវាសុខាភិបាល

៥- សូមបង-ប្អូនរួមជាតិទាំងអស់ ចូលរួមលើកទឹកចិត្ត និងមិនត្រូវរើសអើងឬមាក់ងាយអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ឡើយ

៦- សូមអំពាវនាវដល់ក្រុមបុរសរួមភេទជាមួយបុរស ក្រុមអ្នកបំប្លែងភេទ ក្រុមស្ត្រីបម្រើសេវានៅតាមគ្រឹះស្ថានកម្សាន្តសប្បាយមនុស្សពេញវ័យ។ល។ ត្រូវចូលរួមក្នុងការអនុវត្តនូវវិធានការបង្ការការចម្លងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ ដើម្បីសុខភាពផ្ទាល់ខ្លួន និងដើម្បីទប់ស្កាត់ការចម្លងថ្មី និងឈានទៅបញ្ចប់ជំងឺអេដស៍ នៅឆ្នាំ២០២៥ ឱ្យបានសម្រេចជោគជ័យ។

ជាទីបញ្ចប់នេះ ខ្ញុំសូមជូនពរ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ក្មួយៗ យុវជន និងបងប្អូនជនរួមជាតិទាំងអស់ សូមប្រកបតែនឹងព្រះពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ នឹង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

*ថ្ងៃ សុក្រ ១២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧*

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២៣*

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**